CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន #032820C**

**3/28/2020**
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov
ពលរដ្ឋ៖ សូមទូរស័ព្ទមកលេខ 562.570.INFO

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ការកែសំរួលបទបញ្ជាសុខភាព "រក្សាសុវត្ថិភាពដោយនៅផ្ទះ" នៃទីក្រុងឡុងប៊ិច

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - នៅថ្ងៃទី ២៨ ខែមីនាឆ្នាំ ២០២០ ទីក្រុងឡុងប៊ិចបានចេញការកែសំរួលបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" ដែលបានចេញដោយមន្រ្តីសុខាភិបាលនៃទីក្រុងឡុងប៊ិចកាលពីថ្ងៃទី ២៤ ខែមីនាឆ្នាំ២០២០ ក្នុងគោលបំណងកាត់បន្ថយការរាលដាលនៃ COVID-19។ ការធ្វើវិសោធនកម្មគឺដើម្បីផ្តល់ព័ត៌មានបន្ថែមនិងបញ្ជាក់អំពីការបិទឆ្នេរសាធារណៈផ្លូវលំសាធារណៈនិងក្បាលផ្លូវលំក្នុងទីក្រុងឡុងប៊ិច។ ការកែប្រែទាំងនេះក៏ដាក់កម្រិតលើនិងពង្រីកការបិទអាជីវកម្មមួយចំនួនដែលតម្រូវដោយបទបញ្ជារបស់មន្រ្តីសុខាភិបាល។ ទីធ្លាបើកចំហនៅឧទ្យាននិងផ្លូវឧទ្យានអាចនៅប្រើបានដោយបុគ្គលម្នាក់ៗសម្រាប់ការថែរក្សាសុខភាពប្រសិនបើអនុវត្តវិធានការណ៍រក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាដែលសមស្រប។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងស្ថិតនៅចំណុចសំខាន់នៃវិបត្តិឈសុខភាពសាធារណៈនេះដូច្នេះវាសំខាន់ណាស់ដែលយើងរក្សាចម្ងាយពីគ្នានិងធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើទៅបានដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគនៅក្នុងសហគមន៍របស់យើង។"

ការបិទកន្លែងកម្សាន្តតាមឆ្នេរនិងសាធារណៈត្រូវបានពន្យាពេលដល់ថ្ងៃទី ១ ខែឧសភាឆ្នាំ ២០២០ ខណៈដែលការបិទនិងការកម្រិតចំពោះអាជីវកម្មមានប្រសិទ្ធិភាពរហូតដល់ថ្ងៃទី ១៩ ខែមេសាឆ្នាំ ២០២០ ឬរហូតដល់មានការជូនដំណឹងបន្ថែម។ សេចក្តីសង្ខេបនៃអ្វីដែលបានផ្លាស់ប្តូរនៅក្នុងបទបញ្ជាត្រូវបានគូសបញ្ជាក់ដូចខាងក្រោមៈ

**អាជីវកម្មសំខាន់ៗត្រូវខិតខំប្រឹងប្រែងដើម្បីធានានូវការអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាក្នុងចំណោមនិយោជិកដែលរួមមានៈ**

- ការអនុញ្ញាតឱ្យមានការធ្វើការពីផ្ទះ ការប្រជុំតាមវីដេអូឬទូរស័ព្ទ ការបង្កើតកាលវិភាគការងារផ្សេងៗគ្នាដើម្បីធានាថាចំនួនមនុស្សដែលធ្វើការនៅក្នុងការិយាល័យក្នុងពេលតែមួយមានតិច ការបំបែកនិយោជិកឱ្យនៅចម្ងាយ ៦ ហ្វីតពីគ្នា។
- ដាក់កម្រិតលើការប្រជុំឬការជួបជុំជាពិសេសនៅទីតាំងដែលនិយោជិកអាចធ្វើអន្តរកម្មឬអាចមានការទាក់ទងជាមួយសមាជិកសាធារណៈ។
    - នេះរាប់បញ្ចូលទាំងការដាក់កម្រិតលើឬការលុបចោល (១) ការដែលនិយោជិកធ្វើដំណើរតាមយានយន្តជាមួយគ្នា និង/ឬ (២) ការតម្រូវឱ្យនិយោជិកធ្វើការងារជាក្រុមចាប់ពីពីរនាក់ឡើងទៅ។
    - ប្រសិនបើការប្រជុំឬការជួបជុំគឺពិតជាចាំបាច់នោះអាជីវកម្មសំខាន់ៗត្រូវតែអនុវត្តការរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាក្នុងកម្រិតដែលអាចអនុវត្តបាន។

**ទីតាំងដែលត្រូវបិទនិងទីតាំងដែលឥឡូវត្រូវបានបិទៈ**

- ឆ្នេរសមុទ្រសាធារណៈទាំងអស់ ផ្លូវលំ ក្បាលផ្លូវលំ ទីធ្លាលេងកីឡាបោះបាល់ ទីលានលេងតិនីស ទីលានបាល់ទះ ទីលានវាយកូនហ្គោល សួនសត្វឆ្កែ សួនកុមារ ទីលានជិះស្គី សួនសាធារណៈ និងចំណតរថយន្តសាធារណៈនៅមាត់សមុទ្រ ក៏ដូចជាកន្លែងកំសាន្តពិចនិច។
- កន្លែងហាត់ប្រាណឯកជននៅក្នុងអគារលំនៅដ្ឋានពហុដូចជានៅក្នុងអគារខុនដូនិងអាផាតមិន (អាគារផ្ទះល្វែង)។

**អាជីវកម្មដែលលែងចាត់ទុកជា "សំខាន់"ៈ**

- អាជីវកម្មដែលលក់ផលិតផលថែខ្លួន (ឧទាហរណ៍ហាងលក់ផលិតផលរក្សាសម្រស់)

**ការកំរិតលើអាជីវកម្មសំខាន់ៗ៖**

- សេវាកម្មថែទាំមរណភាពត្រូវបានកំណត់ចំពោះការយកចេញការថែទាំការរៀបចំនិងការបញ្ចុះសពមនុស្សឬសត្វដែលបានស្លាប់តែប៉ុណ្ណោះ។ ការប្រារព្ធពិធីបុណ្យសពមិនអនុញ្ញាតទេ។
- សេវាកម្មលាបថ្នាំគឺអនុញ្ញាតលុះត្រាតែ (១) គោលបំណងនៃការលាបបពណ៌គឺដើម្បីលក់ឬជួលទីលំនៅថ្មី (២) ការលាបថ្នាំគឺចាំបាច់ដើម្បីរក្សាសុវត្ថិភាពឬស្ថានភាពរស់នៅនៃទីលំនៅឬអាជីវកម្មឬ (៣) ការលាបបពណ៌គឺដោយសារតែការសាងសង់ថ្មី។

**ការដាក់កំរិតបន្ថែម៖**

- មន្ទីរព្យាបាលជំងឺដោយប្រើកញ្ឆាដែលមានការអនុញ្ញាតអាចបើកដោយមានការមកយកតាមដងផ្លូវជាបណ្តោះអាសន្នក្រោមល័ក្ខខ័ណ្ឌដូចខាងក្រោម៖
    - ការទូទាត់ប្រាក់សម្រាប់កញ្ឆា និង/ឬ ផលិតផលកញ្ឆាត្រូវទូទាត់មុនដែលមកយកតាមដងផ្លូវ។
    - អ្នកជំងឺត្រូវបញ្ជូនភស្តុតាងនៃអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាលដែលមានសុពលភាពនិងអត្តសញ្ញាណប័ណ្ណវេជ្ជសាស្ត្ររបស់អ្នកជំងឺមុនពេលទៅដល់កន្លែងចត។
    - ពេលមកយកផលិតផលខាងហាងត្រូវតែបញ្ជាក់ថាអ្នកជម្ងឺគឺជាមនុស្សតែមួយនឹងអ្នកដែលបានបញ្ជាទិញដោយការសូមពិនិត្យមើលអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាល។
    - ផលិតផលត្រូវតែបញ្ជូនទៅឱ្យអ្នកជំងឺដោយវេចខ្ចប់នឹងកញ្ចប់ដែលស្រអាប់ហើយមិនអាចមើលឃើញដល់ក្នុងបាន។
    - បុគ្គលិកសន្តិសុខដែលពាក់ឯកសណ្ឋាននិងមានអាជ្ញាប័ណ្ណត្រូវតែមានវត្តមានក្នុងកំឡុងពេលអតិថិជនមកយករបស់តាមដងផ្លូវគ្រប់ប្រភេទ។
    - រាល់បទប្បញ្ញត្តិនិងបទបញ្ជាស្របច្បាប់របស់ទីក្រុងនិងរដ្ឋគឺត្រូវគោរព។

**ការអនុវត្តន៍ច្បាប់៖**

- ឥឡូវនេះទីក្រុងអាចចេញសំបុត្រពិន័យរដ្ឋបាលប្រឆាំងនឹងអាជីវកម្មដែលធ្វើប្រតិបត្តិការរំលោភលើបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ"។
- មន្ទីរទឹកដោយពិគ្រោះយោបល់ជាមួយមេធាវីក្រុងអាចនឹងបិទសេវាកម្មផ្គត់ផ្គង់ទឹកដល់អាជីវកម្មដែលមិនចាំបាច់ដែលធ្វើប្រតិបត្តិការដោយរំលោភលើបទបញ្ជានេះបើសមស្រប។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាម អំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #